# រដ្ឋាភិបាលកម្ពុជាត្រូវធានាសុវត្ថិភាពដល់ព្រះសង្ឃ

## *កាត់ទោសប៉ូលិសដែលបានពាក់ព័ន្ធក្នុងការបង្ក្រាប «តាមរបៀបប្រទេសភូមា»*

*(ទីក្រុងញូយ៉ក ២១ ធ្នូ ២០០៧)- អង្គការឃ្លាំមើលសិទ្ធិមនុស្ស* (Human Rights Watch) បានថ្លែងនៅក្នុងថ្ងៃនេះថារដ្ឋាភិបាលកម្ពុជាត្រូវធានានូវសុវត្ថិភាពរបស់ព្រះសង្ឃ ដែលប៉ូលិសបានវាយប្រហារអំឡុងពេលធ្វើការតវ៉ាដោយសន្តិវិធីមួយ

*កាលពីថ្ងៃទី១៧ ធ្នូ ប៉ូលិសកូដកម្មប្រដាប់ដោយដំបងអគ្គិសនីឆក់ បានវាយដំព្រះសង្ឃខ្មែរក្រោមមួយក្រុមដែលមាន៤៧អង្គ ជាជនជាតិខ្មែរភាគតិចមកពីភាគខាងត្បូងនៃប្រទេសវៀតណាម ពេលដែលព្រះសង្ឃទាំងនោះ បានព្យាយាមផ្ញើញត្តិមួយច្បាប់ទៅកាន់ស្ថានទូតវៀតណាមនៅទីក្រុងភ្នំពេញ ដែលបានជំទាស់ការដាក់គុកព្រះសង្ឃនៅប្រទេសវៀតណាម ។ លោកស្នងការប៉ូលិសក្រុងភ្នំពេញ ទូច ណារ៉ុថ បានប្រកាសថាអាជ្ញាធរកំពុងធ្វើការស៊ើបអង្កេតលើព្រះសង្ឃទាំងអស់ដែលបានតវ៉ា ដើម្បីស្វែងរក «ព្រះសង្ឃក្លែងក្លាយដែលញុះញង់ឲ្យមានអំពើហិង្សា»*

*លោកស្រីសូភី រីឆាតសុន ជាតំណាងឲ្យអង្គការឃ្លាំមើលសិទ្ធិមនុស្ស បាននិយាយថា ៈ«ព្រះសង្ឃខ្មែរក្រោមបានទទួលរងការរំលោភពីប៉ូលិសនៅក្នុងប្រទេសកម្ពុជា ហើយអាចជាប់គុកនិងទារុណកម្មប្រសិនបើត្រូវគេបញ្ជូនទៅប្រទេសវៀតណាមវិញ ។ រដ្ឋាភិបាលកម្ពុជាមិនត្រូវយកគំរូតាមប្រទេសភូមាដោយបានបង្ក្រាបព្រះសង្ឃដែលបានតវ៉ាដោយសន្តិវិធីនោះឡើយ ។ ព្រះសង្ឃទាំងនេះគឺជាប្រជារាស្ត្រកម្ពុជាដែលសមទទួលបានការការពារ តែមិនមែនការធ្វើទុក្ខទោសកាន់តែច្រើនឡើង ពីសំណាក់រដ្ឋាភិបាលកម្ពុជា»*

*អង្គការឃ្លាំមើលសិទ្ធិមនុស្សព្រួយបារម្ភថាអាជ្ញាធរកម្ពុជានឹងចាប់ផ្សឹក និងបញ្ជូនដោយបង្ខំពពួកព្រះសង្ឃដែលបានតវ៉ាទៅកាន់ប្រទេសវៀតណាម ដែលទីនោះព្រះសង្ឃទាំងនោះអាចឈមមុខនឹងការសងសឹកវិញយ៉ាងធ្ងន់ធ្ងរ ។ ប្រទេសវៀតណាមមានគោលនយោបាយមួយក្នុងការដាក់គុកដល់អ្នកធ្វើការរិះគន់ដោយសន្តិភាពចំពោះរដ្ឋាភិបាល រួមមានបព្វជិតសាសនាកាតូលិក ព្រះសង្ឃព្រះពុទ្ធសាសនា អ្នកច្បាប់សិទ្ធិមនុស្ស និងសកម្មជនសហជីពពាណិជ្ជកម្ម*

រដ្ឋាភិបាលកម្ពុជាបាន "បញ្ជូន" ខ្មែរក្រោមត្រឡប់ទៅប្រទេសវៀតណាមវិញ ទោះបីច្បាប់អន្តរជាតិហាមឃាត់ការបណ្តេញចេញអ្នកណាម្នាក់ពីប្រទេសដែលពួកគេរស់នៅយ៉ាងស្របច្បាប់ ដោយគ្មានដំណើរការកាត់ទោសដោយតុលាការក៏ដោយ ។

ឧទាហរណ៍នៅក្នុងខែមិថុនា ឆ្នាំ២០០៧ ព្រះសង្ឃខ្មែរក្រោមទឹម សាខន ដែលជាព្រះចៅអធិការវត្តគង់នៅយូរវស្សាក្នុងប្រទេសកម្ពុជា ត្រូវបានចាប់ផ្សឹកដោយអាជ្ញាធរប្រទេសកម្ពុជា ។ ព្រះអង្គត្រូវបានបញ្ជូនទៅកាន់ប្រទេសវៀតណាម ដែលគេបានកាត់ទោសឲ្យជាប់ពន្ធនាគារពីបទរំលោភលើនយោបាយឯកភាពជាតិនៃប្រទេសវៀតណាម ពីព្រោះគេចោទព្រះអង្គថាបានចែកចាយព្រឹត្តិប័ត្រស្តីអំពីនយោបាយនិងប្រវត្តិសាស្ត្រខ្មែរក្រោម និងផ្តល់ជំរកដល់ប្រជាជនខ្មែរក្រោមដែលរត់ភៀសខ្លួនពីប្រទេសវៀតណាម ។

ក្នុងខែកុម្ភះ ២០០៧ អាជ្ញាធរវៀតណាមបានចាប់ផ្សឹក និងដាក់គុកព្រះសង្ឃខ្មែរក្រោមក្នុងខេត្តសុកត្រាំង(ខ្មែរក្រោមហៅខេត្តឃ្លាំង) នៅប្រទេសវៀតណាម ដោយសារធ្វើការតវ៉ាដោយសន្តិវិធីគាំទ្រសុំឲ្យមានសេរីភាពខាងសាសនា ។ ព្រះសង្ឃប្រាំអង្គត្រូវបានកាត់ទោសឲ្យជាប់គុកក្នុងប្រទេសវៀតណាមពីបទធ្វើឲ្យរំខានដល់សណ្តាប់ធ្នាប់សង្គម ។ បន្ទាប់មក ព្រះសង្ឃខ្មែរក្រោមរាប់សិបអង្គបានរត់គេចខ្លួនពីប្រទេសវៀតណាមមកកាន់ប្រទេសកម្ពុជា ដែលព្រះសង្ឃទាំងនោះបានធ្វើការតវ៉ាក្នុងខែកុម្ភះនិងខែមេសា សុំអំពាវនាវឲ្យដោះលែងព្រះសង្ឃប្រាំអង្គនោះ ។

លោកស្រីរីឆាតសុនបានមានប្រសាសន៍ថាៈ « យើងមានការព្រួយបារម្ភយ៉ាងខ្លាំងអំពីសុវត្ថិភាពរបស់ខ្មែរក្រោម ដែលធ្វើការតវ៉ាទាំងនៅក្នុងប្រទេសកម្ពុជាក្តីប្រទេសវៀតណាមក្តី»

បន្ទាប់ពីព្រះសង្ឃខ្មែរក្រោមបានធ្វើការតវ៉ានៅក្រៅបរិវេណស្ថានទូតវៀតណាមនៅទីក្រុងភ្នំពេញកាលពីថ្ងៃទី២៧ ខែកុម្ភះ ឆ្នាំ២០០៧ ព្រះសង្ឃមួយអង្គក្នុងចំណោមព្រះសង្ឃដែលបានធ្វើការតវ៉ាត្រូវបានរកឃើញស្លាប់នៅក្នុងវត្តដែលព្រះអង្គគង់ ដែលព្រះអង្គត្រូវបានអារកជាច្រើនដង ។ ប៉ូលិសបានប្រកាសថាព្រះសង្ឃអង្គនោះបានធ្វើអត្តឃាត បានបញ្ជាឲ្យបញ្ចុះសពយ៉ាងរួសរាន់ ហើយហាមប្រាមព្រះសង្ឃឯទៀតធ្វើបុណ្យសពឡើយ ។

ព្រះសង្ឃដែលត្រូវផ្សឹកមួយចំនួនដែលបានរត់គេចមកកាន់ប្រទេសកម្ពុជាពីប្រទេសវៀតណាមកាលពីដើមឆ្នាំនេះ ត្រូវបានបំបួសឡើងវិញជាបន្តបន្ទាប់ដោយចៅអធិការគង់នៅកម្ពុជា ។ តែទោះជាយ៉ាងណាក៏ដោយ ព្រះសង្ឃទាំងនោះភាគច្រើនមិនត្រូវបានផ្ដល់ឲ្យនូវ អត្តសញ្ញាណប័ណ្ណ សម្គាល់ព្រះសង្ឃជាផ្លូវការដោយក្រសួងធម្មការនិងឃោសនាឡើយ ។ មានន័យថាអាជ្ញាធរប្រទេសកម្ពុជាអាចជំទាស់នឹងភាពស្របច្បាប់ជាព្រះសង្ឃ ដោយប្រើប្រាស់ជាមូលដ្ឋានដើម្បីចាប់ព្រះសង្ឃដែលថាជា "ព្រះសង្ឃក្លែងក្លាយ" ហើយបញ្ជូនព្រះសង្ឃទាំងនោះដោយបង្ខំទៅប្រទេសវៀតណាម ។

## ព្រឹត្តិការណ៍តវ៉ានៅថ្ងៃទី១៧ ធ្នូ

នៅវេលាប្រមាណម៉ោង៨:០០ព្រឹក ថ្ងៃទី១៧ធ្នូ ព្រះសង្ឃខ្មែរក្រោមមួយក្រុមដែលមាន៤៧អង្គបានប្រមូលគ្នានៅស្ថានទូតវៀតណាមនៅទីក្រុងភ្នំពេញ ។ ព្រះអង្គបានបញ្ជូនញត្តិអំពាវនាវសុំឲ្យរដ្ឋាភិបាលវៀតណាមដោះលែងព្រះសង្ឃខ្មែរក្រោមប្រាំមួយអង្គចេញពីគុក សុំឲ្យដោះស្រាយជម្លោះដីធ្លីដែលកើតចេញ ពីការរឹបអូសយកដីស្រែចំការរបស់ខ្មែរក្រោមនៅប្រទេសវៀតណាមក្រោយឆ្នាំ១៩៧៨ និងសុំឲ្យគោរពសិទ្ធិ របស់ជនជាតិភាគតិច ។

ការទាមទារជាលាយលក្ខណ៍អក្សររបស់ព្រះសង្ឃខ្មែរក្រោមដែលបានបង្ហាញនៅថ្ងៃទី១៧ ខែធ្នូនោះ ពុំបានអំពាវនាវប្រគល់ឲ្យប្រទេសកម្ពុជាវិញនូវទឹកដីដែលគេស្គាល់ថាកម្ពុជាក្រោម ដែលបារាំងបានប្រគល់ឲ្យវៀតណាមនៅក្នុងឆ្នាំ១៩៤៩ ។ ព្រះសង្ឃបានសុំឲ្យមានដំណោះស្រាយអំពីជម្លោះដីធ្លីដែលកើតចេញពីការទន្ទ្រានយកដីធ្លីដែលជាកម្មសិទ្ធិរបស់ប្រជាជនខ្មែរក្រោមដោយអាជ្ញាធរវៀតណាមនិងពលរដ្ឋវៀតណាមភាគតិចជាពិសេសចាប់តាំងពីឆ្នាំ១៩៧៨ ។ នៅពេលនោះរដ្ឋាភិបាលវៀតណាមបានជន្លៀសខ្មែរក្រោមឲ្យតាំងទីលំនៅថ្មីដោយបង្ខំឲ្យចាកចេញឆ្ងាយពីដីស្រែដែលនៅជិតព្រំដែនប្រទេសកម្ពុជា ដោយសារការវាយប្រហារឆ្លងកាត់ព្រំដែនជាមួយខ្មែរក្រហម ។

ប៉ូលិសកូដកម្មរាប់សិបនាក់ដែលកាន់ខែលនិងព្រនង់ឈើនិងដំបងអគ្គីសនីឆក់ ខ្លះប្រដាប់ដោយអាវុធុនវែងវាយប្រហារនិងកាំភ្លើងខ្លីធុនរ៉ឺវ៉ុលវែរ បានឡោមព័ទ្ធជុំវិញស្ថានទូតវៀតណាម ។ ប៉ូលិសបានថតរូបព្រះសង្ឃទាំងអស់ រួមទាំងអ្នកសង្កេតការណ៍សិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ និងកម្ពុជា ។ ប៉ូលិសកូដកម្មកាន់តែច្រើនបានមកដល់ភ្លាមៗ រហូតដល់ជាង៦០នាក់នៅកន្លែងនឹងកន្លែង ។

បន្ទាប់ពីការចរចាគ្នារវាងប៉ូលិសនិងព្រះសង្ឃព្រះសង្ឃប្រាំអង្គត្រូវបានអនុញ្ញាតិឲ្យចូលកាន់ឃ្លាំងទ្វារដើម្បីប្រគល់ញត្តិ ។ នៅម៉ោង៨ៈ៤០ព្រឹក ដោយពុំមានអ្នកណាម្នាក់ពីស្ថានទូតចេញមកទទួលញត្តិ ព្រះសង្ឃមួយក្រុមធំបានចាប់ផ្ដើមរុលទៅមុខជិតច្រកទ្វារចូលស្ថានទូត ។ ប៉ូលិសបានប្រើខែលរបស់ខ្លួនដើម្បីរុញច្រានព្រះសង្ឃឲ្យថយក្រោយវិញ ដោយបានវាយព្រះសង្ឃមួយអង្គចំត្រង់ក្បាល ។ មានការប៉ះទង្គិចគ្នាខ្លះបានកើតឡើង ។

ព្រះសង្ឃមានលទ្ធភាពបើកផ្លូវដើរឆ្លងកាត់ជួរប៉ូលិស ហើយបានចាប់ផ្ដើមនិមន្តសំដៅច្រកទ្វារចូលស្ថានទូត ។ មេបញ្ជាការដែលជាស្នងការរងប៉ូលិសម្នាក់បានស្រែកបញ្ជាឲ្យប៉ូលិស «ចាប់វាបាញ់ចោល ។ បើវានៅតែក្បាលរឹង បាញ់ទៅ» ប្រសិនបើនៅតែបន្តដើរទៅមុខសំដៅស្ថានទូត ។ ព្រះសង្ឃបានអង្គុយចុះនៅលើចិញ្ចើមផ្លូវដើរ ហើយចាប់ ផ្ដើមសូត្រធម៌ ។ ប្រហែលម៉ោង៩ៈ០០ព្រឹក ប៉ូលិសបង្ក្រាបកូដកម្មប្រាំបីនាក់ទៀតបានមកដល់ ។ ពួកគេបានដេរប្រទេចយ៉ាងកំរោល ហើយបាននិយាយឡុកឡឺយដាក់ព្រះសង្ឃ ដែលព្រះសង្ឃមួយចំនួនបានដៀមដាមដាក់ប៉ូលិសវិញ ។

ប្រមាណម៉ោង៩ៈ៣០ព្រឹក ព្រះសង្ឃបានក្រោកឈរឡើង ដោយព្រះសង្ឃមួយចំនួនបានព្យាយាមសំដៅទៅកាន់ស្ថានទូតម្ដងទៀត ។ បន្ទាប់មកប៉ូលិសបានប្រើខែលនិងព្រនង់ឈើវាយព្រះសង្ឃនៅត្រង់ក្បាល ដៃ ក្រលៀន និងស្មា ឆក់ព្រះសង្ឃនឹងដំបងអគ្គិសនី វាយនឹងកណ្ដាប់ដៃ ទាត់ធាក់ព្រះសង្ឃនឹងស្បែកជើងកវែងរបស់ពួកគេ ។ ព្រះសង្ឃបានព្យាយាមការពារខ្លួនដោយប្រើដៃជើង-ដោយពាក់តែស្បែកជើងផ្ទាត់ប៉ុណ្ណោះ- ហើយបានចោលដបទឹកសុទ្ធផ្លាស្ទិកទៅលើប៉ូលិស ។ ព្រះសង្ឃខ្លះបាន គ្រវីថង់ដែលនៅជាប់ស្មាដាក់បូលិស ។

បន្ទាប់មកព្រះសង្ឃបានបែរហើយរត់គេច ។ ប៉ូលិសបានដេញតាមដោយបានឆ្លងកាត់ប្លូនផ្លូវដោយទាត់ធាក់និងវាយព្រះសង្ឃនៅតាមផ្លូវហើយ វាយយុវជនក្មេងម្នាក់ដែលបានព្យាយាមរើសយកស្បែក ជើងផ្ទាត់និងថង់របស់ព្រះសង្ឃមួយអង្គដែលត្រូវបានវាយឲ្យសន្លប់ ។ ប៉ូលិសបានស្រែកធ្វើឲ្យភ្ញាក់អ្នក ដើរឆ្លងកាត់ផ្លូវនៅពេលពួកគេបានដេញតាមព្រះសង្ឃដែលឆ្លងកាត់ថ្នល់ដោយនិយាយថាៈ«យើងវាយនេះមិន មែនជាព្រះតេជគុណ» ។

ព្រះសង្ឃប្រាំមួយអង្គបានរងរបួសជាទម្ងន់ ដោយព្រះសង្ឃមួយអង្គពកក្បាលយ៉ាងធំមួយអង្គទៀត បានដួលសន្លប់បន្ទាប់ពីត្រូវបានឆក់នឹងដំបងអគ្គីសនីឆក់ ហើយជាច្រើនអង្គទៀតរងរបួសត្រង់ជើងនិងជង្គង់ ។មន្រ្តីប៉ូលិសមួយចំនួនបានទទួលរងស្នាមដាច់រលាត់និងជាំបន្តិចបន្តួច ។

អង្គការឃ្លាំមើលសិទ្ធិមនុស្សសូមអំពាវនាវដល់រដ្ឋាភិបាលកម្ពុជាស៊ើបអង្កេតជាបន្ទាន់និងដោយមិនលំអៀងទៅលើការប្រើកម្លាំងប៉ូលិសមកលើព្រះសង្ឃ ហើយកាត់ទោសអ្នកដែលទទួលខុសត្រូវក្នុងការប្រើប្រាស់អំពើហឹង្សាដែលមិនចាំបាច់ហួសហេតុពេក ។

គោលការណ៍ជាមូលដ្ឋានរបស់អង្គការសហប្រជាជាតិអំពីការប្រើប្រាស់កម្លាំងនិងអាវុធដោយមន្រ្តីអនុវត្តច្បាប់ចែងថា មន្ត្រីពង្រឹងច្បាប់ក្នុងពេលអនុវត្តភារកិច្ចរបស់ខ្លួន ត្រូវប្រើមធ្យោបាយអហឹង្សាតាមដែលអាចធ្វើទៅបានមុននឹងប្រើកម្លាំងជាជម្រើសចុងក្រោយ ។ នៅពេលណាការប្រើកម្លាំងដែលមិនអាចជៀសវាងបាននោះមន្ត្រីពង្រឹងច្បាប់ត្រូវតែប្រើការទប់ស្កាត់និងប្រពឹត្តទៅតាមសមាមាត្រនៃភាពធ្ងន់ធ្ងរនៃការបំពាននោះ ។គោលដៅដោយស្របច្បាប់គួរតែត្រូវសម្រេចបានដោយមានការខូចខាតនិងរងរបួសតិច បំផុត ។

លោកស្រីឆោតសុនមានប្រសាសន៍ថាៈ «សូម្បីតែបន្ទាប់ពីព្រះសង្ឃបានចាកចេញពីស្ថានទូតហើយក្តីប៉ូលិសបន្តវាយព្រះសង្ឃយ៉ាងខ្លាំងបន្ទាប់ពីការតវ៉ាត្រូវបានបំបែករួច ។ប្រសិនជាប៉ូលិសចង់បំបែកក្រុមបាតុករនិងចាប់ខ្លួនបាតុករហេតុអ្វីពួកគេបានដេញតាមហើយវាយព្រះសង្ឃទាំងនោះ? »

កាលពីអតីតកាល ព្រះសង្ឃខ្មែរក្រោមមានលទ្ធភាពអាចឆ្លងកាត់ពីប្រទេសវៀតណាមដោយសេរីដោយពុំមានទិដ្ឋាការ ដើម្បីសិក្សាពុទ្ធសាសនានៅសាលាបាលីនៅប្រទេសកម្ពុជា ។ ចាប់តាំងការបង្ក្រាបកាលពីខែកុម្ភះ២០០៧នៅប្រទេសវៀតណាមនិងបាតុកម្មដោយព្រះសង្ឃខ្មែរក្រោមនៅទីក្រុងភ្នំពេញមកទោះជាយ៉ាងណាក៏ដោយ រដ្ឋអំណាចប្រទេសកម្ពុជាបានបង្កនូវផលលំបាកកាន់តែខ្លាំងដល់ព្រះសង្ឃមកពីប្រទេសវៀតណាមក្នុងការទទួលបានការអនុញ្ញាតិពីព្រះចៅអធិការវត្តដើម្បីបានស្នាក់នៅក្នុងប្រទេសកម្ពុជា ខណៈពេលកំពុងសិក្សានៅទីនោះ ។

លើសពីនេះទៀត រដ្ឋអំណាចកម្ពុជាបានគំរាមកំហែងព្រះសង្ឃខ្មែរក្រោមនៅទីក្រុងភ្នំពេញ ខេត្តបន្ទាយមានជ័យ និងខេត្តកំពង់ស្ពឺជាមួយនឹងការបណ្តេញចេញពីវត្ត ឬគំរាមចាប់បញ្ជូនដោយបង្ខំត្រឡប់ទៅប្រទេសវៀតណាមវិញប្រសិនបើពួកគេប្រទះឃើញខ្មែរក្រោមចែកចាយព្រឹត្តិប័ត្រខ្មែរក្រោមដែលសរសេរ រាយការណ៍អំពីបញ្ហាវប្បធម៌ សាសនា និងនយោបាយ ឬប្រទះឃើញចូលរួមក្នុងការតវ៉ាណាមួយ ។

ក្នុងខែមិថុនា ក្រសួងធម៌ការនិងសាសនារបស់ប្រទេសកម្ពុជាបានចេញបទបញ្ជាមួយហាមប្រាមព្រះសង្ឃពុទ្ធសាសនាមិនឲ្យចូលរួមធ្វើបាតុកម្ម ។

លោកស្រីរីឆាតសុនបាននិយាយថាៈ «រដ្ឋាភិបាលកម្ពុជាគួរតែគោរពការប្តេជ្ញាចិត្តរបស់ខ្លួនចំពោះសិទ្ធិធ្វើបាតុកម្មដោយអហឹង្សា និងសិទ្ធិបញ្ចេញមតិដោយសេរីដូចបានដាក់ដឹកល់នៅក្នុងច្បាប់រដ្ឋធម្មនុញប្រទេសកម្ពុជា និង សិទ្ធិសញ្ញាសិទ្ធិមនុស្សជាច្រើនទៀតដែលខ្លួនបានចុះហត្ថលេខា»